ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ០៨១/ ១៨ គជប

# របាយការណ៍បូកសរុប
## សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រីមាសទី១ និងទិសដៅត្រីមាសទី២ ឆ្នាំ២០១៨

(គិតចាប់ពីថ្ងៃទី ០១ ខែ មករា ដល់ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១៧)

## I. ស្ថានភាពទូទៅ

ក្នុងខែត្រីមាសទី១ ឆ្នាំ២០១៨ ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាបជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយស្ថាប័ន អន្តរក្រសួង និងអង្គភាពពាក់ព័ន្ធនានា ជាពិសេសលេខាធិការដ្ឋាន គ.ខ.ប.ជ ថ្នាក់ក្រោមជាតិ។ ដោយឡែកការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍ ក៏មានស្ថានភាពមិនប្រក្រតី រហូតដល់រាជរដ្ឋាភិបាលកម្ពុជាដែលមានសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ បានមានប្រសាសន៍នៅក្នុងកម្មវិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ របស់រដ្ឋបាលខេត្តបាត់ដំបង និងបញ្ជាក់ថា "**ឆ្នាំ២០១៨ ត្រូវបិទច្រករបៀងឲ្យបាន**" ពីព្រោះវាមិនមែនតែទំនិញគេចពន្ធ និងគ្រឿងញៀនទេ វាជាច្រកមានការរត់ពន្ធមនុស្ស ជួញដូរមនុស្ស ដែលជាបញ្ហាគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋយើង ត្រូវបានគេនាំចេញទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ រហូតដល់ជាងមួយលាននាក់ (ទាំងស្របច្បាប់ ទាំងមិនមានឯកសារច្បាប់លាស់) និងការខាតបង់ថវិកាជាតិរាប់លានដុល្លារ។ ក្រោយពីរាជរដ្ឋាភិបាលថៃ បានចេញគោលការណ៍រឹតបន្តឹងពលករទេសសន្តរប្រវេសន៍ ធ្វើការខុសច្បាប់ក្នុងប្រទេសថៃរួចមក ដើម្បីជាដំណោះស្រាយ ប្រមុខរាជរដ្ឋាភិបាលរបស់យើង បានយកចិត្តទុកដាក់បំផុតចំពោះប្រជាពលរដ្ឋ ធ្វើទេសន្តរប្រវេសយ៍នៅក្រៅប្រទេស និងបានសហការជាមួយរដ្ឋាភិបាលថៃ ក្នុងការជំរុញឲ្យមានការរៀបចំផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ជាពិសេសត្រូវបានពិភាក្សាជាមួយភាគីថៃ ដើម្បីការការពារសុវត្ថិភាព សិទ្ធិការងារ ក្នុងនោះរួមមានរបបគ្រោះថ្នាក់ការងារ របបថែទាំសុខភាព និងប្រាក់សោធននិវត្តន៍ជូនដល់ពលករកម្ពុជា ឲ្យដូចពលករថៃដែរ។

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន **គ.ជ.ប.ជ** ជាសេនាធិការ បានបន្តសម្របសម្រួល ពង្រឹងកិច្ចសហការជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ ប្រមូលផ្តុំកម្លាំងចូលរួមរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព រាជធានី-ខេត្ត ដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរកដំណោះស្រាយបញ្ហាប្រឈមនានា។

ជាលទ្ធផល ដែលសម្រេចបានក្នុងខែត្រីមាសទី១ ឆ្នាំ២០១៧នេះ មានដូចខាងក្រោមៈ

# ការអនុវត្តផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ (២០១៤-២០១៨)

## ក. ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

### ក.១-ការងារច្បាប់ គោលនយោបាយលិខិតបទដ្ឋានជាតិ និងកិច្ចសហប្រតិបត្តិការ

#### ក.១-ច្បាប់ គោលនយោបាយលិខិតបទដ្ឋានជាតិ និងកិច្ចសហប្រតិបត្តិការកំពុងរៀបចំ

ក.១.១-សេចក្តីព្រាងច្បាប់បានចុះហត្ថលេខារួចៈ

- លោកជំទាវអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.ប.ជ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីជាមួយឥណ្ឌា ស្តីពី"អនុស្សរណៈនៃការយោគយល់គ្នាស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស" (ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៨)។

ក.១.២-សេចក្តីព្រាងច្បាប់ដែលកំពុងរៀបចំៈ

- សេចក្តីព្រាងច្បាប់ ស្តីពី"ការពពោះជំនួស"(ក្រសួងកិច្ចការនារី និងក្រសួងយុត្តិធម៌)។
- ក្រសួងយុត្តិធម៌បានរៀបចំសេចក្តីព្រាងច្បាប់ចំនួន០២គឺៈ
  - ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (MLA)
  - ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

ក.១.៣-លិខិតបទដ្ឋានកិច្ចសហប្រតិបត្តិការអន្តរជាតិកំពុងរៀបចំៈ

- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្តីព្រាងចុះលើសន្ធិសញ្ញា ទ្វេភាគីរួមមានៈ
  - សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
    រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ
    រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលបារាំង
    រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលកូរ៉េខាងត្បូង។
  - សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"បត្យាប័ន"
    រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលឥណ្ឌា។
  - សេចក្តីព្រាង កិច្ចព្រមព្រៀង ស្តីពី "បញ្ជូនទណ្ឌិត"
    រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលអង់គ្លេស
    រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលប៉េរូ
    រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ។

ក.១.៤-លិខិតបទដ្ឋានជាតិកំពុងរៀបចំៈ

- សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត "សម្រាប់អនុវត្តល័ក្ខខ័ណ្ឌការងារកម្មករការងារផ្ទះ" (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)។
- សេចក្តីព្រាងគោលនយោបាយ ស្តីពី "កិច្ចការការពារកុមារតាមសាលារៀន" (ក្រសួងអប់រំ យុវជន និងកីឡា)។
- សេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍ (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា)។

Ritha

❖ អនុស្សរណៈរវាងអង្គការដៃគូដែលបានចុះហត្ថលេខារួចៈ

- គណៈកម្មាធិការជាតិ គ.ជ.ប.ជ បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយសមាគមមូនិធិឈាន ឆាយ ដើម្បីមនុស្សធម៌ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស នៃពលករទេសន្តរប្រវេសន៍នៅប្រទេសថៃ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨។

❖ កំពុងរៀបចំអនុស្សរណៈជាមួយអង្គការដៃគូ ៖

- គណៈកម្មាធិការជាតិ គ.ជ.ប.ជ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គការអន្តរជាតិ GVC ស្តីពី"ការគាំទ្រ និងការតស៊ូមតិលើសិទ្ធិពលករទេសន្តរប្រវេសន៍កម្ពុជា ក្នុងប្រទេសថៃ ដើម្បីទប់ស្កាត់ការរំលោភបំពានអំពើជួញដូរមនុស្ស"។
- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International។
- ក្រសួងសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រីលើកទី២ ស្តីពីការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី ស្តីពីការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។

## ខ.ការបង្ការទប់ស្កាត់

### ខ.១-ការកាត់បន្ថយតាពរងគ្រោះដល់ជនមុខសញ្ញារងគ្រោះ៖

រដ្ឋបាលខេត្តចំនួន២ ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានជួយសម្រួល និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ សរុបចំនួន១១.៨៤៦ក្បាល ក្នុងនោះមានៈ (ខេត្តបន្ទាយមានជ័យចំនួន៧.០៤១ក្បាល និងខេត្តបាត់ដំបង៤.៨០៥ក្បាល) ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន។

### ខ.២-ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ

នៅត្រីមាសទី១ ឆ្នាំ២០១៨នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចសហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈ ក្នុងការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំមានសុវត្ថិភាព**" ដល់អាជ្ញាធរមូលដ្ឋាន សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ បានចំនួន១៣.២២១លើក មានអ្នកចូលរួមសរុបចំនួន៨៩៧.១១៣នាក់ (ធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៧ មានចំនួនត្រឹមតែ៨៤០.២៣០នាក់) កើនឡើងចំនួន៥៦.៨៨៣នាក់ ស្មើនឹង៦.៧៦% ក្នុងនោះស្ត្រីមានចំនួន៤៥៥.១៣៦នាក់។ (**ឧបសម្ព័ន្ធទី១**)

### ខ.៣-ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន

-លេខាធិការដ្ឋានគ.ខ.ប.ជ បានចូលរួមផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមប៉ុស្តិ៍វិទ្យុចំនួន១១២លើក (ខេត្តកោះកុង៩០លើក សៀមរាប១៩លើក កំពង់ចាម០១លើក និងបាត់ដំបង០២លើក)។

- ខេត្តសៀមរាបៈ
  - **អង្គការ** Friend International គម្រោងកល្យាណមិត្ត បានធ្វើការចែកខិត្តប័ណ្ណ និងសំភារៈផ្សព្វផ្សាយដែលមានខ្លឹមសារទាក់ទាងនឹងកិច្ចការពារកុមារ មានដូចជា៖
    - គន្លឹះទាំង៧សម្រាប់ជួយដល់កុមារ ចំនួន៤៦៦សន្លឹក

Fitha

- គន្លឹះទាំង៧សម្រាប់ជនបរទេស ចំនួន៩១៤សន្លឹក
- កាតទូរស័ព្ទបន្ទាន់ ចំនួន ៨៨៤សន្លឹក
- លេខទូរស័ព្ទបន្ទាន់នៅលើផូស្ទ័រ ចំនួន៤០ផូស្ទ័រ
- ភ្នាក់ងារសុវត្ថិភាពកុមារ ចំនួន៦៣អាវ
- ភ្នាក់ងារសុវត្ថិភាពកុមារ ចំនួន១០៦ស្ទីកគ័រ
- រក្សាកុមារនៅក្នុងគ្រួសារ/សហគមន៍ (មណ្ឌលកុមារកំព្រាធ្វើឲ្យកុមារបែកចេញពីគ្រួសារ) ចំនួន៨៥ផូស្ទ័រ
- កុមារមិនមែនជាឧបករណ៍សំរាប់ទាក់ទាញកុមារទេ ចំនួន៨៦សន្លឹក
- និងបានលើកស្លាកទូរស័ព្ទបន្ទាន់ ចំនួន១២រឺម៉កម៉ូតូកង់បី។

- ខេត្តបាត់ដំបង អង្គការ **Samaritan Purse** បានសហការជាមួយសមត្ថកិច្ច ចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករចំណាកស្រុក២០៣នាក់ ស្រី៦៦នាក់ ដែលបញ្ជូនត្រឡប់ពីព្រំដែនប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

**ខ.៤-វិធានការបង្ការ ទប់ស្កាត់ របស់អគ្គស្នងការនគរបាលជាតិ**

ខ.៤.១.-<u>វិធានការទប់ស្កាត់ការធ្វើចំណាកស្រុក</u>

- វរៈនគរបាលការពារព្រំដែនគោកលេខ(៨១៧, ៨១៩, ៨២៣ និង៣១០) ខេត្តបាត់ដំបង បានធ្វើការទប់ស្កាត់ពលករខ្មែរ ដែលបំរ៉ុងធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ បានចំនួន០២លើក មនុស្សចំនួន០៦នាក់ ស្រី០២នាក់ អនីតិជន០៣នាក់។
- ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានធ្វើការទប់ស្កាត់ពលករខ្មែរ ដែលបំរ៉ុងធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ បានចំនួន០១លើក មនុស្សចំនួន០២នាក់(អនីតិជន)។

ខ.៤.២-<u>វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ៖</u>

អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍ពីក្រុមការងារអនុវត្តន៍ច្បាប់) និងស្នងការរាជធានី-ខេត្ត បានសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពបង្ការទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផលដូចខាងក្រោម ៖

- កម្លាំងជំនាញនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន៦១១គោលដៅ មានមនុស្សចំនួន២.០៣៧នាក់ (ស្រី១.៥៣២នាក់)។
- គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទ ក្នុងនោះអំពើជួញដូរមនុស្សចំនួន០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន៦៦គោលដៅ សរុបចំនួន៧៥គោលដៅទូទាំងរាជធានី-ខេត្ត។
- ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន៤២លើក ខេត្តអនុវត្តមាន៖ ឧត្តរមានជ័យ ស្ទឹងត្រែង កំពង់ធំ ព្រៃវែង ព្រះវិហារ និងមណ្ឌលគិរី។

- **ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ និងអង្គការម្លប់តាប៉ាង** បានដាក់បណ្តាញភ្នាក់ងារ ដើម្បីការពារសុវត្ថិភាពកុមារ មានក្រុមម៉ូតូឌុប ក្រុមម៉ូតូកង់បីចំនួន១៤៣នាក់ ផ្ទះសំណាក់ សណ្ឋាគារ២៤កន្លែង អ្នកលក់តាមឆ្នេរសមុទ្រ៧១នាក់ បណ្តាញតាមសហគមន៍៦០នាក់ ផ្នែកភ្នាក់ងារទេសចរណ៍០២នាក់ សមាជិកបណ្តាញបុគ្គលិកផ្ទះសំណាក់/សណ្ឋាគារ៣៧៤នាក់។
- **ស្នងការដ្ឋាននគរបាលខេត្តសៀមរាប និងអង្គការ Friend InTernation** គម្រោងកល្យាណមិត្ត បានដាក់បណ្តាញភ្នាក់ងារដើម្បីការពារសុវត្ថិភាពកុមារ ដល់ក្រុមម៉ូតូឌុប ក្រុមម៉ូតូកង់បីចំនួន៤៥នាក់។

**ខ.៥-គោលនយោបាយប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់**

ខ.៥.១-<u>វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក</u>

ការធ្វើបច្ចុប្បន្នភាពលើទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស ប្រចាំខែនីមួយៗ បានពិនិត្យឃើញថា នៅតែបន្តកើតមានឡើង ជាក់ស្តែងត្រីមាសទី១ ឆ្នាំ២០១៨នេះ មានតួលេខ ដូចខាងក្រោម៖

***<u>តារាងតាមដានបច្ចុប្បន្នភាពលើទិន្នន័យពលករខ្មែរចំណាកស្រុក ប្រចាំត្រីមាសទី១</u>***

| ប្រចាំខែ | សរុបរួម | | | | ស្របច្បាប់ | | | | មិនស្របច្បាប់ | | | | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | |
| | | | សរុប | ស្រី | | | សរុប | ស្រី | | | សរុប | ស្រី | |
| មករា | ៣០០.០៧៧ | ១២៧.៧៤៩ | ៨.៤៧៨ | ៣.១៦៥ | ១៦៨.០៤២ | ៧៤.៦៣៥ | ៩៥៦ | ៤២៧ | ១៣២.០៣៥ | ៥៣.១១៤ | ៧.៥២២ | ២.៧៣៨ | ថយចុះ ២១.៥២០ |
| កុម្ភៈ | ២៨៨.២៦៣ | ១២៦.៨២៩ | ៨.៥១៣ | ៣.១៦៦ | ១៥៧.១៤៧ | ៧៣.៦៥៨ | ៩៩៧ | ៤២៧ | ១៣១.១១៦ | ៥៣.១៧១ | ៧.៥១៦ | ២.៧៣៩ | ថយចុះ ១១.៨១៤ |
| មីនា | ២៦០.២២៨ | ១១៤.១២៩ | ៦.៨៨០ | ២.៤៧៩ | ១៥៥.៣៧៧ | ៧០.៩៩៥ | ៤២៨ | ១៥៣ | ១០៤.៨៥១ | ៤៣.១៣៤ | ៦.៤៥២ | ២.៣២៦ | ថយចុះ ២៨.០៣៥ |

ខ.៥.២-<u>ស្ថិតិពលករ ដែលអាជ្ញាធរបរទេសបានចាប់បញ្ជូនមកវិញតាមច្រកព្រំដែន</u>

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន៤៧០លើក មានមនុស្សចំនួន១០.១២៧នាក់ (ស្រី៣.៥៤១នាក់ កុមារ៨៧៧នាក់)។ ក្នុងនោះតាមច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ចំនួន៧៨លើក មនុស្ស១៦១នាក់ ស្រី៧០នាក់ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន៣៨៦លើក មនុស្ស៩.៩២៣នាក់ (ស្រី៣.៤៤៦នាក់ កុមារ៨៧៧នាក់) និងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម ចំនួន០៦លើក មនុស្ស៤៣នាក់ ស្រី២៥នាក់។

<u>របាយការណ៍ពីស្ថានភាព</u> ៖

- ក្រុមការងារអនុវត្តច្បាប់៖ អាជ្ញាធរថៃបានឃាត់ខ្លួនពលរដ្ឋខ្មែរចំនួន៦៤៣នាក់ ពីបទឆ្លងដែនខុសច្បាប់ និងបានឃាត់ខ្លួនលើសរយៈពេល១ខែមុននឹងបញ្ជូនមកកម្ពុជាវិញ។
- របាយការណ៍របស់មន្ត្រីអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិដូង ស្រុកកំរៀង ខេត្តបាត់ដំបង បានទទួល សពពលករឆ្លងដែនចំនួន២០នាក់ (ស្រី០១នាក់)។
- ខេត្តបន្ទាយមានជ័យ អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោមរូបភាព «និរទេស» តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត សរុបមានចំនួន២៥៩ជើង/រថយន្ត សរុបមានមនុស្សចំនួន៩.៩៣៥នាក់ ស្រី៣.៤៦០នាក់ ក្នុងនោះកុមារ៩២៦នាក់ កុមារី ៤២៤នាក់។ បើប្រៀបធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៧ ចំនួន១៥.៦៤៥នាក់ គឺមានការថយចុះចំនួន៥.៧១០នាក់ ស្មើនឹង៣៦.៤៩%។

Rtha

- ចេញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតចំនួន២.៧៦១នាក់ តាមច្រករបៀងចំនួន ៧.១៧៤នាក់ ក្នុងនោះចេញដោយខ្លួនឯងចំនួន៣.៧៧៨នាក់ និងតាមមេខ្យល់ចំនួន៦.១៥៧នាក់។
- បើតាមការសម្ភាសន៍៖ កុមារ២៨៣នាក់ មានកុមារី៩៨នាក់ រកឃើញថាទៅតាមឪពុកម្តាយមាន២៣១នាក់ និងទៅតាមបងប្អូនមាន៥២នាក់។

- **ខេត្តបាត់ដំបង** បានទទួលពលករខ្មែរដែលអាជ្ញាថៃបញ្ជូនត្រឡប់មកវិញ ចំនួន៨៩លើក មនុស្សចំនួន៨៥៣នាក់ ស្រី៣៥៩នាក់ កុមារ១៧នាក់។
- **ខេត្តប៉ៃលិន** បានទទួលពលករខ្មែរដែលអាជ្ញាថៃបញ្ជូនត្រឡប់មកវិញ ចំនួន៩០លើក មនុស្សចំនួន៨៦៧នាក់ ស្រី៣៣៥នាក់។

- **ដោយឡែក** យោងរបាយការណ៍អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានបង្ហាញថាមានជនបរទេសធ្វើការនៅកម្ពុជាដោយខុសច្បាប់ ត្រូវបានរកឃើញដូចខាងក្រោម ៖

១-<u>ការងារអនុវត្តនីតិវិធី និងការបណ្តេញចេញជនបរទេសខុសច្បាប់:</u> ជនបរទេសដែលល្មើសច្បាប់ស្តីពីអន្តោប្រវេសន៍ ត្រូវបានបណ្តេញពីព្រះរាជាណាចក្រកម្ពុជា មានចំនួន ១៧២លើក មានមនុស្សចំនួន២៥៧នាក់ ស្រី១២នាក់ ៖

- អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ចំនួន៧៦លើក មនុស្ស១២៤នាក់ ស្រី១២នាក់។
- ការបដិសេធមិនឲ្យចូលប្រទេសតាមប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ និងក្រុមផ្តល់ទិដ្ឋាការ ចំនួន៩៦លើក មនុស្ស១៣៣នាក់។

២-បទល្មើសស្នាក់នៅខុសច្បាប់ សរុបមានមនុស្សចំនួន២៤នាក់ ស្រី០៣នាក់ និងមាន ១០សញ្ជាតិដែលចែកជា៖

- ស្នាក់នៅខុសច្បាប់ មានមនុស្ស១០នាក់ ស្រី០៣នាក់ និងមាន០៥សញ្ជាតិ (មានជនជាតិឈីលី មីយ៉ាន់ម៉ា បារាំង រុស្ស៊ី និងអូស្រ្តាលី)។
- ស្នាក់នៅគ្មានលិខិតឆ្លងដែន មានមនុស្ស០២នាក់ មាន០២សញ្ជាតិ(មានជនជាតិឥណ្ឌា និងអ៊ីតាលី)។
- ស្នាក់នៅលើសទិដ្ឋាការ មានមនុស្ស១០នាក់ មាន០៣សញ្ជាតិ (មានជនជាតិនីហ្សេរីយ៉ា០៧នាក់ អ៊ុយក្រែន០២នាក់ ចិនដីគោក០១នាក់)។
- ករណីប្រើប្រាស់ឯកសារក្លែងក្លាយ មានមនុស្ស០២នាក់ មាន០២សញ្ជាតិ (មានជនជាតិណាមីប៊ី និងឥណ្ឌា)។

**ខ.៦-ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរនិងជនបរទេស**

ក្រុមការងារច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសជាពិសេស នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសចំនួន៣៥៨គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅនារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេសតាមរយៈទូរស័ព្ទផ្ទាល់ចំនួន៣២នាក់ ដើម្បីតាមដានស្ថានភាពដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

Ritha

## គ.ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះ ទទួលបានពីអង្គភាពចំនួន១៤ គឺ៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត (រាជធានីភ្នំពេញ បាត់ដំបង បន្ទាយមានជ័យ កំពង់ចាម កំពង់ឆ្នាំង កណ្តាល ព្រះវិហារ សៀមរាប ព្រះសីហនុ តាកែវ ឧត្តរមានជ័យ និងខេត្តត្បូងឃ្មុំ)។

**គ.១-ការងារអនុវត្តច្បាប់**

គ.១.១-ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន៣៤/៤១ករណី (បើប្រៀបធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៧ មានការថយចុះចំនួន០៧ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន៤៦/៤៦នាក់ (ស្រី១១នាក់) ក្នុងនោះជនសង្ស័យជាអនីតិជន ០៥នាក់ និងជនបរទេស១២នាក់ មានសញ្ជាតិ (អង់គ្លេស០៥នាក់ កាណាដា០២នាក់ អូស្រ្តាលី០១នាក់ ណកវេស០១នាក់ នីឡឺឡែន០១នាក់ ញ៉ូសាលែន០១នាក់ និងហ្វីលីពីន០១នាក់)។ យើងបានសង្គ្រោះជនរងគ្រោះចំនួន៦០/៧២នាក់ ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ២៣នាក់ អាយុពី១៥-១៧ឆ្នាំ០៨នាក់ និងអាយុ១៨ឆ្នាំឡើង២៩នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច២៧នាក់ និងគ្រួសារចំនួន៣៣នាក់)។

**១.ករណីអំពើជួញដូរមនុស្ស៖**

បង្ក្រាបបាន០៩/០៨ករណី (កើនឡើងចំនួន០១ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន១០នាក់ (ស្រី០៥នាក់) សង្គ្រោះជនរងគ្រោះចំនួន១២នាក់ ក្នុងនោះ៖ អាយុក្រោម១៥ឆ្នាំ០៥នាក់ អាយុពី១៥-១៧ឆ្នាំ០៣នាក់ និងអាយុ១៨ឆ្នាំឡើង០៤នាក់ (ប្រគល់ឲ្យគ្រួសារចំនួន១២នាក់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ |
|---|---|---|
| -ការនាំអនីតិជនចេញក្រៅប្រទេស មិនស្របច្បាប់ | ០៥ | ០៦ |
| -ការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០១ | ០១ |
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០១ | ០១ |
| -អំពើលក់ដូរមនុស្សដោយមានគោលដៅ | ០១ | ០១ |
| -ការទទួលយកមនុស្សដោយជួយដល់ជនល្មើស | ០១ | ០១ |
| *សរុប* | *០៩ ករណី* | *១០ នាក់* |

**២.អំពើធ្វើអាជីវកម្មផ្លូវភេទ៖**

បង្ក្រាបបាន២៥/៣៣ករណី (ថយចុះចំនួន០៨ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន៣៦នាក់ (ស្រី០៦នាក់) ជនសង្ស័យជាអនីតិជន០៥នាក់ និងជនបរទេស១២នាក់ មានសញ្ជាតិអង់គ្លេស០៥នាក់ កាណាដា០២នាក់ អូស្រ្តាលី០១នាក់ ណកវេស០១នាក់ នីឡឺឡែន០១នាក់ ញ៉ូសាលែន០១នាក់ និងហ្វីលីពីន០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន៤៨នាក់ ក្នុងនោះ៖ អាយុក្រោម១៥ឆ្នាំ១៨នាក់ អាយុ១៥-១៧ឆ្នាំ០៥នាក់ និងអាយុ១៨ឆ្នាំឡើង២៥នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន២៧នាក់ និងប្រគល់ឲ្យគ្រួសារចំនួន២១នាក់) ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -ស្ថានទម្ងន់ទោសការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ០១ | ០១ | អូស្ត្រាលី១ |
| -សញ្ចារកម្ម | ០២ | ០៣ | អង់គ្លេស៥ កាណាដា២ |
| -សញ្ចារកម្ម (មានអនីតិជន) | ០២ | ០២ | ណាកវេស១ នីជីឡែន១ |
| -ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | ០១ | ០២ | ញ៉ូហ្សេលែន១ |
| -រូបភាពនិងសម្ភារៈអាសអាភាស | ០២ | ១១ | ហ្វីលីពីន១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១១ | ១១ | |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៦ | ០៦ | |
| *សរុប* | *១០ ករណី* | *៣៦ នាក់* | *១២ នាក់* |

**គ.២-កិច្ចការយុត្តិធម៌**

គ.២.១-លទ្ធផលចំណាត់ការផ្តន្ទាទោស

ទិន្នន័យទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ មាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ មានដូចខាងក្រោម៖

គ.២.២-ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ៖

ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត សរុបមានចំនួន៣៣ករណី ជនរងគ្រោះចំនួន៣៨នាក់ (អនីតិជន២៦នាក់) ជនត្រូវចោទមានចំនួន៣៩នាក់ ហើយបានចំណាត់ការដោយបានបញ្ជូនទៅស៊ើបសួរចំនួន២០ករណី, តម្កល់ទុកឥតចាត់ការ០១ករណី និងកំពុងចាត់ការចំនួន១២ករណី ដូចមានតារាងរាយលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនល្មើស | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | បញ្ជូនទៅស៊ើបសួរ | តម្កល់ទុកឥតចាត់ការ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | |
| សរុប | ២ | ១០ | ៦ | ២០ | ៣៤ | ៥ | ០ | ០ | ២០ | ១ | ១២ |
| ៣៣ | ១២នាក់ | | ២៦នាក់ | | ៣៩នាក់ | | គ្មាន | | ៣៣ករណី | | |

គ.២.៣-ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត ៖

ចំណាត់ការរបស់ចៅក្រមស៊ើបសួរ រាជធានី-ខេត្ត សរុបមានចំនួន១៥៥ករណី ជនរងគ្រោះ១៨៤នាក់ (អនីតិជន១១៣នាក់) ជនត្រូវចោទមានចំនួន២១៤នាក់ (អនីតិជន៣៤នាក់) នៅក្នុងឃុំចំនួន១៥៧នាក់ (អនីតិជន៥០នាក់) នៅក្រៅឃុំ៥៧នាក់ (អនីតិជន២៣នាក់) និងបានចំណាត់ការបញ្ជូនទៅជម្រះចំនួន១៩ករណី លើកលែងចោទគ្មាន និងកំពុងចាត់ការចំនួន១៣៦ករណី ដូចមានតារាងរាយលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមស៊ើបសួរ៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | នៅក្នុងឃុំ | | | | នៅក្រៅឃុំ | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | ជូនទៅជម្រះ | លើកលែងចោទ | កំពុងចាត់ការ |
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | | | |
| សរុប ១៥៥ | ១១ | ៦០ | ១ | ១១២ | ១៦៣ | ១៧ | ៣៤ | ០ | ៨៧ | ២០ | ១៨ | ៣២ | ២២ | ១២ | ១២ | ១១ | ១៩ | ០ | ១៣៦ |
| | ៧១នាក់ | | ១១៣នាក់ | | ១៨០នាក់ | | ៣៤នាក់ | | ១៥៧នាក់ | | | | ៥៧នាក់ | | | | ១៥៥ករណី | | |

គ.២.៤-ចំណាត់ការរបស់ចៅក្រមជំនុំជម្រះ រាជធានី-ខេត្ត ៖

ចំណាត់ការរបស់ចៅក្រមជំនុំជម្រះរាជធានី-ខេត្ត សរុបមានចំនួន៥៤ករណី ជនរងគ្រោះចំនួន៧០នាក់ (អនីតិជន២៦នាក់) ជនជាប់ចោទសរុប៧២នាក់ (ស្រី១១នាក់) និងបានចំណាត់ការ ទោសព្យួរគ្មានពិន័យជាគ្មាន រួចផុតពីបទចោទគ្មាន រំលត់បណ្តឹងអាជ្ញាគ្មាន ចាត់ការរួចគ្មាន ផ្តន្ទាទោសពន្ធនាគារ ក្នុងឃុំ១៨នាក់ ក្រៅឃុំ២៤នាក់ និងកំពុងចាត់ការ៣៦ករណី។

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមជំនុំជម្រះ៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនជាប់ចោទ | | ប្រភេទចំណាត់ការ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | | | ទោសព្យួរ | ពិន័យជាប្រាក់ | រួចផុតពីបទចោទ | រំលត់បណ្តឹងអាជ្ញា | ចាត់ការរួច | ផ្តន្ទាទោសពន្ធនាគារ | | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | | | ក្នុងឃុំ | ក្រៅឃុំ | |
| សរុប ៥៤ | ១ | ៤៣ | ០ | ២៦ | ៦៥ | ១១ | ០ | ០ | ០ | ០ | ១៨ | ១៨ | ២៤ | ៣៦ |
| | ៤៤នាក់ | | ២៦នាក់ | | ៧២នាក់ | | | | | | | | | |

## ឃ.កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

ឃ.១-ការសម្ភាសពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញារងគ្រោះ និងជនសង្ស័យ (មករា និងខែកុម្ភៈ)

- យោងស្ថិតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជូនពលរដ្ឋខ្មែររងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស និងបានសហការជាមួយអង្គការ IOM មានចំនួន៦៣នាក់ ស្រី៣០នាក់ មកពី ៖

- ប្រទេសម៉ាឡេស៊ី ចំនួន៣៣នាក់ (ស្រី០៦នាក់)
- ប្រទេសថៃ ចំនួន១៥នាក់ (ស្រី០៩នាក់)
- ប្រទេសវៀតណាម ចំនួន០៧នាក់ (ស្រី០៧នាក់)
- ប្រទេសចិន ចំនួន០៦នាក់ (ស្រី០៦នាក់)
- ប្រទេសសឹង្ហបុរី ចំនួន០២នាក់ (ស្រី០២នាក់)។

*<u>ស្ថាប័ន-អង្គភាពអនុវត្តមាន ៖</u>*

○ អង្គការ IOM ក្នុងខែមករា ឆ្នាំ២០១៨នេះ បានជួយសម្រួលការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋ ពលករពលការនីរងគ្រោះចំនួន១១នាក់ មកពីប្រទេសម៉ាឡេស៊ី។

○ អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍តាមក្រុមការងារអនុវត្តន៍ច្បាប់) បានទទួលពលករខ្មែររងគ្រោះចំនួន៣៥នាក់(ស្រី១៩នាក់) ក្នុងនោះមកពីប្រទេសម៉ាឡេស៊ី១៤នាក់, ចិន១៣នាក់

ថៃ០៥នាក់ និងប្រទេសអារ៉ាប៊ីសាអូឌី០៣នាក់។ តាមការសម្ភាសទៅតាមមេខ្យល់២៧នាក់ទៅដោយខ្លួនឯង០៥នាក់ និងទៅតាមក្រុមហ៊ុន០៣នាក់។

**ឃ.២-ការទទួលជនសង្ស័យរងគ្រោះ**

យោងរបាយការណ៍ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការងារការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានាសរុបចំនួន៤៦នាក់ (ស្រី២៥នាក់) ។ មានដូចខាងក្រោម៖

- បានទទួលជនរងគ្រោះធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា ចំនួន៤៣នាក់ ស្រី២៥នាក់ ក្នុងនោះមកពី៖ ប្រទេសវៀតណាម១១នាក់ ចិន០៩នាក់(ករណីជួញដូរផ្លូវភេទ) ម៉ាឡេស៊ី២២នាក់ និងអារ៉ាប់ប៊ីសាអូឌីត០១នាក់ (ករណីជួញដូរកម្លាំងពលកម្ម)។

- មជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានទទួលសាវតាជនរងគ្រោះដោយអំពើជួញដូរមនុស្សមុនពេលធ្វើមាតុភូមិនិវត្តន៍ ដើម្បីស្វែងរកគ្រួសារចំនួន០៨នាក់ ស្រី០៣នាក់ ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស នៃប្រទេសថៃ(DSDW) និងបានទទួលជនរងគ្រោះធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃចំនួន០៣នាក់ ករណីជួញដូរកម្លាំងពលកម្ម (ទូកនេសាទ)។

**ឃ.៣-ការស្តារនីតិសម្បទាជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស** (ក្រុមការងារការពារជនរងគ្រោះ)

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិម្បទាចំនួន១៥០នាក់ (ស្រី៩៦នាក់) ក្នុងនោះមាន៖

- មជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានធ្វើការសម្ភាសកំណត់អត្តសញ្ញាណជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស (ដែលបាននីរទេសពីប្រទេសថៃ) ចំនួន៥៦នាក់ ស្រី១៨នាក់ កុមារ៣៥នាក់ កុមារី១៥នាក់ និងបានបញ្ជូនបន្តទៅអង្គការតំណក់ទឹក៤១នាក់ និងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ១៥នាក់។
- មន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ បានចុះសង្គ្រោះ និងសហការទទួលនារីរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន៥៧នាក់ (កុមារី០៦នាក់) និងបានបញ្ជូនបន្តទៅអង្គការដៃគូ។
- អង្គការដៃគូ បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន៣៧នាក់ ស្រី២១នាក់ ក្នុងនោះមាន៖ អង្គការពន្លកថ្មី១៨នាក់ អង្គការ HAGAR ០៥នាក់ និងអង្គការសង្គ្រោះជោគវាសនាកម្ពុជា១៤នាក់។

**ឃ.៤-ការធ្វើសមាហរណកម្មជួយជនរងគ្រោះ និងជនងាយរងគ្រោះ (ក្រុមការពារជនរងគ្រោះ)**

- **ការធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្ម ជួយជនរងឲ្យទៅតាមសហគមន៍វិញ សរុបចំនួន១៣៥នាក់ (ស្រី១៣៤នាក់) ក្នុងនោះមាន៖

- មន្ទីរសង្គមកិច្ចខេត្តពោធិ៍សាត់ បានសហការជាមួយអធិការដ្ឋានក្រុងពោធិ៍សាត់សង្គ្រោះជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទចំនួន០៤នាក់(ស្រី) រួចបានធ្វើសមាហរណកម្មទៅសហគមន៍វិញចំនួន០៣នាក់ និង០១នាក់ទៀតបញ្ជូនទៅអង្គការមេត្រីអន្តរជាតិ។
- មន្ទីរសង្គមកិច្ចខេត្តស្វាយរៀង តាកែវ និងខេត្តកំពង់ធំ បានសមាហរណកម្មជនរងគ្រោះទៅគ្រួសារនិងសហគមន៍វិញចំនួន៤០នាក់(ស្រី)។

Pitha

- អង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះទៅកាន់គ្រួសារ និងសហគមន៍វិញចំនួន៥៣នាក់ ស្រី៥២នាក់ ក្នុងនោះមានអង្គការដូចជាៈ អង្គការសួននៃក្តីសង្ឃឹមកម្ពុជា៣២នាក់ អង្គការ HAGAR០៣នាក់ និងអង្គការជោគវាសនាកម្ពុជា១៨នាក់។
- អង្គការមេត្រីអន្តរជាតិ និងអង្គការរតនៈអ៊ិនធើណេសិនណល បានធ្វើសមាហរណកម្មស្ត្រីរងគ្រោះដោយអំពើជួញដូរផ្លូវភេទចំនួន០២នាក់ ទៅសហគមន៍វិញ។
- អង្គការរតនៈអ៊ិនធើណេសិនណល និងអង្គការសួននៃក្តីសង្ឃឹមកម្ពុជា បានចុះតាមដានតិចិជនដែលបានធ្វើសមាហរណកម្មកន្លងមកចំនួន៣៦នាក់(ស្រី) ករណីជួញដូរផ្លូវភេទ០៧នាក់ ជួញដូរកម្លាំងពលកម្ម០៤នាក់ និងករណីរំលោភបំពានផ្លូវភេទ២៣នាក់។

## II. ការលើកកម្ពស់សមត្ថភាព

### ១. ក្នុងប្រទេស

#### ១.១-ការបណ្តុះបណ្តាលក្នុងប្រទេស

លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តចំនួន០៥ គឺមានខេត្តព្រះសីហនុ មណ្ឌលគិរី សៀមរាប ក្រចេះ និងខេត្តរតនគិរី បានសហការជាមួយជំនាញតាមក្រសួង មន្ទីរ អង្គភាព និងអង្គការដៃគូ បើកវគ្គបណ្តុះបណ្តាលបានចំនួន១២វគ្គ មានសិក្ខាកាមចូលរួមចំនួន៥២៣នាក់ ក្នុងនោះមានស្ត្រី៣៦៥នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តន៍ច្បាប់ សមាជិក គ.ខ.ប.ជ លោកគ្រូ អ្នកគ្រូ ប្រតិបត្តិករទេសចរណ៍នៅតាមសណ្ឋាគារ និងប្រជាពលរដ្ឋ ដូចមានតារាងលម្អិតខាងក្រោមៈ

*តារាងវគ្គបណ្តុះបណ្តាល*

| ល.រ | ស្ថាប័នអនុវត្ត និងវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | មន្ទីរទេសចរណ៍ ខេត្តព្រះសីហនុ បានបើកវគ្គបណ្តុះបណ្តាលៈ<br>- ស្តីពីបដិសណ្ឋារកិច្ច សេវាកម្មអាហារ និងភេសជ្ជៈ ចំនួន០២ថ្ងៃ នៅភូមិកោះតូច សង្កាត់កោះរ៉ុង សន្លឹម ក្រុង-ខេត្តព្រះសីហនុ។<br>- ស្តីពីច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធដល់ប្រតិករទេសចរណ៍ និងវិនិយោគិនទេសចរណ៍ចិន បញ្ជ្រាបនិងផ្សព្វផ្សាយក្នុងការចូលរួមទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ទេសចរណ៍ផ្លូវភេទ។ | ០២ | ៦១ | ២៧ |
| ២ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តមណ្ឌលគិរី បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | ០១ | ៥០ | ២៦ |
| ៣ | ខេត្តសៀមរាប អង្គការ Friend International គម្រោងកល្យាណមិត្ត បានបណ្តុះបណ្តាលដល់ភ្នាក់ងារដើម្បីការពារសុវត្ថិភាពកុមារ ជាផ្នែកជួយគាំទ្រការរាយការណ៍សង្គ្រោះជនរងគ្រោះ ដល់ក្រុមគោលដៅ។ | ០១ | ០៤ | |
| ៤ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រចេះ បានបើកវគ្គបណ្តុះបណ្តាលៈ<br>- ស្តីពីកិច្ចការពារជនរងគ្រោះ ការទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពាន និងការធ្វើអាជីវកម្មផ្លូវភេទ។<br>- ស្តីពីកិច្ចការពារជនរងគ្រោះ ការទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពាន និងការធ្វើអាជីវកម្មផ្លូវភេទ។ | ០៧ | ៣៦០ | ២៦៥ |
| ៥ | មន្ទីរកិច្ចការនារី ខេត្តរតនគិរី បានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីសកម្មភាពថ្នាក់ភូមិដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងកិច្ចការពារជនរងគ្រោះ។ | ០១ | ៤៨ | ៤៧ |
| | សរុប | ១២ | ៥២៣ | ៣៦៥ |

១.២-ការងារដឹកនាំសម្របសម្រួល កិច្ចប្រជុំ ៖

សរុបការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ១៩១លើក មានអ្នកចូលរួមសរុប៥.៥៨៣នាក់ មានស្រី៣.៤៩០នាក់ ក្នុងនោះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន៧៤លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ចំនួន៤លើក អគ្គនាយកដ្ឋានអន្តោប្រវេសន៍ចំនួន២៦លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន៨៧លើក ។ (ឧបសម្ព័ន្ធទី២)

## ២. ក្រៅប្រទេស

### ២.១-វគ្គបណ្តុះបណ្តាល

អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចាត់បញ្ជូននាយនគរបាល ចំនួន០២រូប ទៅចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី "ឯកទេសប្រឆាំងនឹងការរត់ពន្ធមនុស្សខុសច្បាប់ និងការរត់ពន្ធជនអន្តោប្រវេសន៍" (នៅប្រទេសសឹង្ហបុរី)។

### ២.២-កិច្ចប្រជុំ

- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជាទៅបំពេញទស្សនកិច្ចជាផ្លូវការ នៅសាធារណរដ្ឋឥណ្ឌា ដែលក្នុងដំណើរទស្សនកិច្ចនោះ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញជាតំណាងដ៏ខ្ពស់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយភាគីឥណ្ឌានូវ "អនុស្សរណៈនៃការយោគយល់គ្នាស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស" ។
- អគ្គនាយកដ្ឋានអន្តោប្រវេសន៍៖
  - សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញបំពេញទស្សនកិច្ចនៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ អមដំណើរក្នុងពេលនោះមានឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត អគ្គនាយកអន្តោប្រវេសន៍ និងប្រតិភូអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ផងដែរ។
  - អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានចាត់បញ្ជូននាយនគរបាលជាន់ខ្ពស់ចំនួន០២រូប ដើម្បីចូលរួមកិច្ចប្រជុំពិភាក្សាតុមូល ចែករំលែកបទពិសោធន៍ជំនាញទេសន្តប្រវេសន៍អ៊ឺរ៉ុប (Magration EU Expertise) នៅប្រទេសថៃ។

## III. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

Pitha

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមជាមួយថ្នាក់តំបន់ និងសកលលោក។
- រាជរដ្ឋាភិបាលបានកំណត់គោលការណ៍ ផែនការសកម្មភាពជាដំណាក់ៗច្បាស់លាស់ និងមានផែនការយុទ្ធសាស្ត្រជាច្រើន ដើម្បីធ្វើសកម្មភាពបង្ការ ទប់ស្កាត់ ការពារ និងបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឲ្យកាន់តែមានប្រសិទ្ធភាព។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានរចនាសម្ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលយន្តការស្នូលក្នុងការអនុវត្ត រួមទាំងអង្គការ វិស័យឯកជន អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ បានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

**ខ. ចំណុចខ្វះខាត**

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅមិនទាន់ចេះសហការគ្នា និងរួមគ្នាធ្វើការជាប្រព័ន្ធ ដើម្បីបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ក្រសួង ស្ថាប័ន ឬអង្គភាព បានធ្វើការងារជាច្រើនទាក់ទងនឹងការងារអំពើជួញដូរមនុស្សតាមវិស័យរបស់ខ្លួន តែរបាយការណ៍ផ្ញើមកគ.ជ.ប.ជ មិនសូវឃើញមានសកម្មភាព។
- របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស ច្រើនជាទូទៅ និងផ្ញើរបាយការណ៍នៅយឺតយ៉ាវមិនទាន់ពេលកំណត់។

**គ.បញ្ហាប្រឈម**

- មន្ត្រីយើងនៅតាមក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅមិនទាន់យល់ច្បាស់ពីការងារដែលទាក់ទងអំពើជួញដូរមនុស្ស ក្នុងវិស័យការងាររបស់ខ្លួន។
- ការសហការគ្នានៅមិនទាន់បានល្អ និងខ្វះធនធានថវិការសម្រាប់អនុវត្ត។

**ឃ.សំណូមពរ**

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជនត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនិមួយៗ ដើម្បីប្រសិទ្ធភាពការងារ។

- ស្នើឲ្យលេខាធិការដ្ឋាន គ.រ/ខ.ប.ជ រាជធានី/ខេត្ត ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ ដើម្បីប្រសិទ្ធភាពការងារ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

### ខ. សន្និដ្ឋាន

- រាជរដ្ឋាភិបាលកម្ពុជាមានការគាំទ្រ និងយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីសុខសុវត្ថិភាព និងភាពរីកចម្រើនក្នុងប្រទេសកម្ពុជា ក្នុងតំបន់ និងលើសកលលោក
- រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ ព្រមទាំងមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសេនាធិការដែលមានឆន្ទៈមោះមុត មានសាមគ្គីភាពទូលាយ មានកិច្ចសហការប្រតិបត្តិការល្អ និងមានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការបំពេញបេសកកម្មប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- មន្ត្រីយើងពីមួយថ្ងៃទៅមួយថ្ងៃ កាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ មានទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន
- ឆ្លងកាត់បទពិសោធន៍ជាច្រើនធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋាន គតិយុត្តិនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន
- ពីមួយថ្ងៃទៅមួយថ្ងៃប្រជាពលរដ្ឋកាន់តែមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស និងមានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយមន្ត្រីបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព។

## IV. ទិសដៅត្រីមាសទី២ ឆ្នាំ២០១៨

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ការពារជន និងបង្ក្រាប ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។

៣. រៀបចំផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(ពាក់កណ្ដាលអាណត្តិទី២៖២០១៧-២០១៨)។

៤. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៥. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៦. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៧. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៨. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៩. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

១០. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១១. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១២. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

**ទិសដៅបន្ថែម ដែលជាអនុសាសន៍សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងកិច្ចប្រជុំឆមាសទី១ នេះ ដែលគប្បីជំរុញអនុវត្ត ឲ្យមានប្រសិទ្ធភាព សម្រាប់ដំណាក់កាលដ៏ចាំបាច់៖**

១៣. ជំរុញអនុវត្តវិធានការ ដែលដាក់ចុះដោយក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស ក្នុងដំណាក់កាលនៃការជំរុញដំណោះស្រាយភាពស្របច្បាប់ដល់ពលករ ដែលនៅក្នុងប្រទេសថៃ និងការទទួលខុសត្រូវរបស់អាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធ ក្នុងការជួយដល់ពលករដែលត្រូវបានបញ្ជូនត្រឡប់។

១៤. បង្កើតក្រុមការងារពិសេសមួយក្រោមគណៈកម្មការផ្តល់ភាពស្របច្បាប់ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្រាវជ្រាវ អំពីពលករខ្មែរ ដែលមានវត្តមានក្នុងប្រទេសថៃ ស្ថានភាពស្របច្បាប់ ឬមិនស្របច្បាប់ ទីកន្លែងធ្វើការ អាស័យដ្ឋាននៅកម្ពុជា ដើម្បីងាយស្រួល ក្នុងការដោះស្រាយបញ្ហា និងទំនាក់ទំនងអប់រំ ផ្តល់សេវា និងបង្កើនភាពជឿជាក់ដល់រាជរដ្ឋាភិបាល។

១៥. រៀបចំបែងចែកក្រុមនេះ ដោយស្នើសុំបញ្ចូលជាក្រុមដែលមានបេសកកម្មពិសេស ជាអនុព័ន្ធការងារ ក្នុងរយៈពេលខ្លីមួយ ដែលនឹងត្រូវរំសាយវិញ ពេលចប់បេសកកម្ម។

១៦. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ...................ខែ..........ឆ្នាំ..........សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី...១៧...ខែ..........ឆ្នាំ២០១៨

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារគ.ជ.ប.ជ
-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## សកម្មភាពផ្សព្វផ្សាយ និងវេទិកាសាធារណៈត្រីមាសទី១ ឆ្នាំ២០១៨

| ល.រ | របាយការណ៍ពី | ខ្លឹមសារសកម្មភាព | អង្គភាព-ស្ថាប័នអ្នករៀបចំ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។ | ស្នងការដ្ឋាននគរបាលខេត្ត | 2,405 លើក | 149,666 នាក់ | 83,124 នាក់ |
| 2 | ខេត្តកណ្តាល | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 994 លើក | 94,870 នាក់ | 44,258 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងកិច្ចការពារជនរងគ្រោះ។ | មន្ទីរទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច មន្ទីរកិច្ចការនារី មន្ទីរអប់រំខេត្ត | 32 លើក | 4,811 នាក់ | 2,837 នាក់ |
| 3 | ខេត្តតាកែវ | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដោយបញ្ជ្រាបក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 126 លើក | 5,699 នាក់ | 1,886 នាក់ |
| | | ផ្សព្វផ្សាយការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត និងមន្ទីរកិច្ចការនារីខេត្ត | 100 លើក | 3,502 នាក់ | 1,633 នាក់ |
| 4 | ខេត្តពោធិ៍សាត់ | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត | 506 លើក | 23,490 នាក់ | 11,870 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈភូមិ-ឃុំមានសុវត្ថិភាព ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ | ស្នងការដ្ឋាននគរបាលខេត្ត | 1,339 លើក | 191,242 នាក់ | 102,446 នាក់ |
| 5 | ខេត្តបាត់ដំបង | ផ្សព្វផ្សាយ ស្តីពីការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត | 2,001 លើក | 90,028 នាក់ | 46,236 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 894 លើក | 28,778 នាក់ | 15,036 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 6 | ខេត្តស្វាយរៀង | ផ្សព្វផ្សាយ ស្តីពីការចំណាកស្រុកដោយសុវត្ថិភាព ដល់កម្មករ កម្មការិនី នៅរោងចក្រ AMPAC តំបន់សេដ្ឋកិច្ចពិសេសមេនហាធេន។ | មន្ទីរការងារ និងបណ្តុះបណ្តាលខេត្ត | 1 លើក | 50 នាក់ | 20 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 683 លើក | 23,392 នាក់ | 12,660 នាក់ |
| 7 | ខេត្តកំពង់ឆ្នាំង | វេទិកាសាធារណៈផ្សព្វផ្សាយ ដល់ប្រជាពលរដ្ឋ ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | ស្នងការដ្ឋាននគរបាលខេត្ត | 1,378 លើក | 50,809 នាក់ | 25,322 នាក់ |
| | | ផ្សព្វផ្សាយលក្ខណៈសម្បត្តិ៩យ៉ាង អំពីគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការទប់ស្កាត់អំពើជួញដូរមនុស្សដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងអង្គការដៃគូ | 1,452 លើក | 61,286 នាក់ | 30,407 នាក់ |
| 8 | ខេត្តសៀមរាប | ផ្សព្វផ្សាយ ស្តីពីការអនុវត្តគោលនយោបាយភូម-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ទូទាំងខេត្ត។ | ស្នងការដ្ឋាននគរបាលខេត្ត | 267 លើក | 12,850 នាក់ | 7,854 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព កិច្ចការពារជនរងគ្រោះ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ។ | មន្ទីរអប់រំ មន្ទីរកិច្ចការនារី កងរាជអាវុធហត្ថខេត្ត និងអង្គការពាក់ព័ន្ធ | 66 លើក | 10,555 នាក់ | 6,528 នាក់ |
| 9 | ខេត្តកំពង់ស្ពឺ | ផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងកិច្ចការពារជនរងគ្រោះ ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 36 លើក | 10,768 នាក់ | 6,159 នាក់ |
| 10 | ខេត្តព្រះវិហារ | ផ្សព្វផ្សាយតាមរយៈគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងស្នងការដ្ឋាននគរបាលខេត្ត | 9 លើក | 601 នាក់ | 127 នាក់ |
